ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

-សាលក្រមលេខ៖ ១៧(ឋ)
-ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២
-សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១២៤៥
-ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង៨,៣០នាទីព្រឹក។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**១/.ដើមចោទ៖**

ឈ្មោះ[redacted] សុជា ភេទប្រុស កើតថ្ងៃទី៣/តុលា/១៩៦៧ សញ្ជាតិខ្មែរ ទីកន្លែងកំណើត[redacted] អាសយដ្ឋានផ្ទះលេខ[redacted] ឪពុកឈ្មោះ ទិម ចេង ម្តាយឈ្មោះ គង់ ពោះម៉ាយ។

<u>អ្នកតំណាងដោយអាណត្តិ</u>៖ មេធាវី [redacted] អត្តលេខ២៣៩១T។

**២/.ចុងចម្លើយ៖** គ្មាន។

## I.អង្គហេតុ និងចំណុចវិវាទ

**ក/.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖**

១.សុំឱ្យតុលាការចេញសាលក្រមបញ្ជាក់មរណភាពប្រពន្ធឈ្មោះ [redacted] *ករុណា* ភេទស្រី។

**ខ/.ដំណើររឿងក្តី និងចំណុចវិវាទ៖**

**ខ១.<u>ការសង្ខេបរឿងក្តី</u>៖**

ដើមចោទឈ្មោះ [redacted]សុជា ភេទប្រុស ត្រូវប្តីរបស់ឈ្មោះ [redacted] ករុណា (ស្លាប់)។ នៅថ្ងៃទី១០/វិច្ឆិកា/២០១១ ឈ្មោះ [redacted] ករុណា បានទទួលមរណភាពដោយរោគាពាធ (ជម្ងឺមហារីក)។ បន្ទាប់ពីឈ្មោះ [redacted] ករុណា ទទួលមរណភាព ក្រុមគ្រួសារជាប់រវល់ធ្វើបុណ្យតាមប្រពៃណី និងមិនដឹងអំពីផ្លូវច្បាប់ត្រូវធ្វើសំបុត្រមរណភាពនៅសាលាសង្កាត់ដែលសាមីខ្លួនរស់នៅ និងទទួលមរណភាព។ ដល់ពេលដែលត្រូវការយកសំបុត្រមរណភាពទៅប្រើប្រាស់លើឯកសារដែលពាក់ព័ន្ធ ទើបដឹងថាពុំបានធ្វើនៅសាលាសង្កាត់។ តែដើម្បីបានឯកសារដែលពាក់ព័ន្ធនឹងសពឈ្មោះ [redacted] ករុណា ទាល់តែមានសាលក្រមពិតុលាការ ទើបប្រើប្រាស់បានតាមផ្លូវច្បាប់។

**ខ២.<u>ការអះអាងរបស់ដើមចោទ</u>៖**

ខ្លួនត្រូវជាប្តីរបស់សពឈ្មោះ [redacted] ករុណា ភេទស្រី ដែលបានទទួលមរណភាពនៅថ្ងៃទី១០/វិច្ឆិកា/២០១១ ដោយជម្ងឺមហារីក។ ខ្លួន និងឈ្មោះ [redacted] ករុណា បានចាប់ដៃគ្នារស់នៅជាប្តីប្រពន្ធ ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។

រហូតដល់ឆ្នាំ២០០១ ពួកខ្លួនទាំងពីបានបង្កើតបានកូនប្រុសម្នាក់ឈ្មោះ [redacted] មករា និងមានទ្រព្យសម្បត្តិរួម ដី និងផ្ទះទំហំ ២៧ម៉ែត្រការ៉េ ស្ថិតនៅភូមិ១៦ សង្កាត់ទន្លេសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ខ្លួន និងប្រពន្ធឈ្មោះ [redacted] ករុណា បានរួមរស់នៅជាមួយគ្នារហូតដល់ឆ្នាំ២០១១ ប្រពន្ធខ្លួនឈ្មោះ [redacted] ករុណា មានជំងឺមហារីកបានស្លាប់ចោលខ្លួននៅថ្ងៃ១០/វិច្ឆិកា/២០១១។ ក្នុងអំឡុងពេលនោះ ខ្លួនមិនបានទៅបញ្ជាក់សំបុត្រមរណភាពពីមន្ត្រីអត្រានុកូលដ្ឋានឡើយ ដោយហេតុថារវល់តែរៀបចំចាត់ចែងកម្មវិធីបុណ្យសព និងមិនបានដឹងថាលិខិតបញ្ជាក់មរណភាពនោះមានសារៈសំខាន់សំរាប់ប្រើប្រាស់នៅពេលក្រោយទេ។ ខ្លួន និងក្រុមគ្រួសារមិនបានដឹង និងយល់អំពីផ្លូវច្បាប់ និងមិនបានទៅចុះបញ្ជីសៀវភៅមរណភាពនៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់នោះទេ។ ពេលខ្លួនទៅធ្វើសំបុត្រមរណភាព គឺការចុះបញ្ជីមរណភាពមិនអាចធ្វើបាន ដោយខ្លួនបានទុកហួសរយៈពេល ហើយមន្ត្រីអត្រានុកូលដ្ឋានមិនអាចចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងមិនអាចចេញសំបុត្រមរណភាពដោយគ្មានសាលក្រមបញ្ជាក់ពីតុលាការបានឡើយ។ ដូច្នេះខ្លួនសុំឱ្យតុលាការ ពិនិត្យភស្តុតាង និងសម្រេចចេញសាលក្រមបញ្ជាក់មរណភាពឱ្យប្រពន្ធខ្លួនឈ្មោះ [redacted] ករុណា ភេទស្រី ដើម្បីឱ្យខ្លួនអាចយកទៅប្រើប្រាស់តាមផ្លូវច្បាប់។

**១៣.ចំណុចវិវាទ៖** គ្មាន។

## II.ការពិនិត្យភស្តុតាង

**១/.ភស្តុតាងជាឯកសាររបស់ដើមចោទ៖**

១.១.សំបុត្របញ្ជាក់កំណើតលេខ៩១៥៤ ចុះថ្ងៃទី១៣/មិថុនា/២០០៥។ (ថតចម្លង)

១.២.សំបុត្របញ្ជាក់កំណើតលេខ៩១៥៣ ចុះថ្ងៃទី១៣/មិថុនា/២០០៥។ (ថតចម្លង)

១.៣.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១១០៧៦៤១១ ចុះថ្ងៃទី០៥/វិច្ឆិកា/២០១៥។ (ថតចម្លង)

១.៤.សៀវភៅស្នាក់នៅលេខ៨០៧៧ ចុះថ្ងៃទី១៧/កុម្ភៈ/២០០០។ (ថតចម្លង)

១.៥.លិខិតឆ្លងដែនលេខ N00990419ផ្តល់ជូនថ្ងៃទី២២/កញ្ញា/២០១៧

១.៦.លិខិតបញ្ជាក់មរណភាពលេខ១២៩១/២១ ល.ប ចុះថ្ងៃទី១២/វិច្ឆិកា/២០២១។ (ថតចម្លង)

**២/.ការសាកសួរសាក្សី៖** គ្មាន។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១/.ការប្តឹងសុំរបស់ដើមចោទដែលទាមទារឱ្យបញ្ជាក់ និងចុះបញ្ជីមរណភាពនេះអាចឱ្យតុលាការធ្វើការវិនិច្ឆ័យបានតាមមាត្រា៣(ញ) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា៩(ជ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២/.សៀវភៅស្នាក់នៅ ចុះថ្ងៃទី១៧/កុម្ភៈ/២០០០ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន ជាភស្តុតាងបញ្ជាក់ឱ្យឃើញថាឈ្មោះ [redacted] សុជា ភេទប្រុស និងឈ្មោះ [redacted] ករុណា ភេទស្រី ពិតជាបានរស់នៅជាមួយគ្នាជាអតីតស្វាមីភរិយាប្រាកដមែន។ គប្បីតុលាការពិនិត្យ និងពិចារណា។

៣/.លិខិតបញ្ជាក់ ចុះថ្ងៃទី១២/វិច្ឆិកា/២០២១ របស់ប្រធានភូមិ១៦ សង្កាត់ទន្លេបាសាក់ ជាភស្តុតាងបញ្ជាក់ឱ្យឃើញថាឈ្មោះ [redacted] ករុណា ភេទស្រី ពិតជាទទួលមរណភាពកាលថ្ងៃទី១០/វិច្ឆិកា/២០១១ ដោយរោគាពាធ (ជំងឺមហារីក) ប្រាកដមែន។ គប្បីតុលាការពិនិត្យ និងពិចារណា។

៤/.ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] សុជា ភេទប្រុស និងការពិនិត្យភស្តុតាងដោយគន្ទានុសិទ្ធនាកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ តុលាការទទួលស្គាល់ថាមានអត្ថិភាពនៃទំនាក់



Scanned with CamScanner

ទំនងគតិយុត្តិដូចការអះអាងរបស់អ្នកប្ដឹងសុំ ប្រាកដមែន។ ដូច្នេះការប្ដឹងសុំរបស់ដើមចោទមានសមហេតុសមរម្យ។ **គប្បីតុលាការសម្រេចទទួលស្គាល់តាមមាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។**

៥/.ដើម្បីផ្ដល់នូវឯកសារគតិយុត្តិដល់ក្រុមគ្រួសារនៃអ្នកស្លាប់។ មន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានអ្នកស្លាប់ ត្រូវចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងចេញសំបុត្រមរណភាពតាមបែបបទនីតិវិធីមាត្រា៤០ថ្មី នៃអនុក្រឹត្យស្ដីការកែសម្រួលអត្រានុកូលដ្ឋានលេខ១៧អនក្រ.បក ចុះថ្ងៃទី១៤/មិថុនា/២០០៤ និងសេចក្ដីណែនាំស្ដីពីការចុះសៀវភៅអត្រានុកូលដ្ឋានលេខ០០៨សណន ចុះថ្ងៃទី១៨/ឧសភា/២០០៧។

៦/.ប្រាក់ប្រដាប់ក្ដីតាមមាត្រា១០ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ជាបន្ទុករបស់ដើមចោទ។

## សេចក្ដីសម្រេចបញ្ចប់

1. បញ្ជាក់ថាឈ្មោះ [redacted] *ករុណា* ភេទស្រី កើតថ្ងៃទី១០/តុលា/១៩៨៨ អាសយដ្ឋាន [redacted] ពិតជាទទួលមរណភាពកាលពីថ្ងៃទី១១/វិច្ឆិកា/២០១១។
2. មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ អនុវត្តករណីយកិច្ចចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនេះ។
3. រ៉ាប់រងប្រាក់ប្រដាប់ក្ដីដែលដើមចោទឈ្មោះ [redacted] សុជា បានបង់រួចហើយ។

ហត្ថលេខា និងត្រា៖ [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៦ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]